សត្វស្រឹងគឺជាសត្វល្អិតដែលស្ថិតក្នុងចំណោមពពួកសត្វចុចជញ្ជក់ទឹកដោះស្រូវ ។ វាជញ្ជក់គ្រាប់ស្រូវក្នុងដំណាក់កាលដាក់ទឹកដោះដែលធ្វើឱ្យគ្រាប់ស្រូវស្កក ជួនកាលវាក៏ចុចជញ្ជក់គ្រាប់ស្រូវនៅក្នុងដំណាក់កាលដាក់ម៉ៀវ បណ្តាលឱ្យគ្រាប់អង្កាមអន់គុណភាព ។

តាមការសង្កេតរបស់យើងកន្លងមកឃើញថាការបំផ្លាញរបស់សត្វល្អិតចង្រៃនេះប្រព្រឹត្តទៅលើស្រែប្រាំងនិងវស្សា ។ ប៉ុន្តែចំពោះស្រែវស្សាសត្វស្រឹងច្រើនធ្វើការបំផ្លាញខ្លាំងលើប្រភេទស្រូវស្រាលជាងស្រូវកណ្តាលនិងស្រូវធ្ងន់ ។

## លក្ខណៈរូប :

- ពងស្រឹងជញ្ជក់ទឹកដោះមានពណ៌ក្រហមត្នោតរាងមូលសំប៉ែតដូចជាស័ក្តរៀបជា ២-៣ ជួរ នៅឯទ្រនុងខ្នងស្លឹក ជួនកាលអាចនៅលើកួរស្រូវក្នុងមេស្រឹង មួយក្បាលអាចពងបានពី ១០ - ២០ ពង ក្នុង ១ លើកៗ ។

-កូនទើបនឹងញាស់មានពណ៌បៃតងភ្លាវ

-មេចំណាស់មានរាងទ្រវែងពណ៌បៃតងស្រអាប់នៅផ្នែកខាងក្រោម ផ្នែកខាងលើមានពណ៌បៃតងត្នោត ។

## ពេលវេលាបំផ្លាញ :

ជាធម្មតាវាចាប់ចេញស៊ីបំផ្លាញនៅពេលព្រឹកព្រលឹមនិងពេលថ្ងៃរសៀលមេឃត្រជាក់ ។

## លក្ខណៈនិងស្លាកស្នាមបំផ្លាញ :

-កូនទើបនឹងញាស់វាស៊ីជញ្ជក់រុក្ខរសដើមស្រូវនិងស្លឹក ។

-មេចំណាស់វាបំផ្លាញដោយចុចជញ្ជក់គ្រាប់ស្រូវនៅដំណាក់កាលស្រូវដាក់ទឹកដោះត្រង់ថ្នេរប្រសព្វរវាងសំបកខ្នងនិងសំបកពោះធ្វើឱ្យគ្រាប់ស្រូវដាក់គ្រាប់មិនពេញ ។ ប្រសិនបើបំផ្លាញក្នុងដំណាក់កាលដាក់ម៉ៀវ វាពុំបណ្តាលឱ្យបាត់បង់ទិន្នផលស្រូវឡើយ តែវាបណ្តាលឱ្យគ្រាប់អង្ករអន់គុណភាព ។

## ការការពារទុកជាមុន :

**អនាម័យស្រែ :** ចំពោះដីស្រែមិនទាន់ដាំដុះត្រូវជំរះស្មៅឱ្យបានស្អាត ដើម្បីបំបាត់ជំរករបស់ស្រឹង ។

**ការដាំព្រមគ្នា :** ត្រូវដាំព្រមគ្នាក្នុងពេលតែមួយនូវពូជស្រូវស្រាលដើម្បីឱ្យស្រូវទាំងនោះទុំព្រមពេលជាមួយគ្នា ។ គ្មានពូជណាដែលធន់ទៅនឹងស្រឹងឡើយ ។

ត្រូវរក្សាសត្វមានប្រយោជន៍ដូចជាពីងពាង, អណ្តើកមាស, កណ្តូបអង់តែនវែង, ឪម៉ាល់ និងកន្ទុំរុយ ។

## វិធានការកំចាត់ :

-ប្រើស្បៃមុងឬសំណាញ់ឈើប ដោយដំបូងត្រូវអូសខ្សែដើរទទឹងស្រែយឺតៗ ប៉ប្រះចុងស្រូវដើម្បីបង្អើលស្រឹងឱ្យហើរមកផ្តុំគ្នានៅខាងមុខរួចសឹមយកឈើបអូសកៀរប្រមូល ឬ ប្រើកន្ត្រងស្បៃមុងចុះត្រវីដងយកអោយបានរហ័ស ហើយប្រមូលយកទៅបុកលាយជាមួយនឹងទឹករួចយកទៅបាញ់លើស្រែ ។

-យកសំបកកង់គ្រប់ប្រភេទដុតបង្ហុយជុំវិញស្រែឬពីលើខ្យល់ដើម្បីឱ្យវាហើរចេញ ។

-យកសាប៊ូក្រអូបលាយជាមួយទឹកបាញ់ទៅលើដើមស្រូវ ។

-យកទឹកម្ទេសទុំបាញ់ទៅលើស្រូវ ក្នុងកំរិតម្ទេសម៉ត់មួយកំប៉ុងទឹកដោះគោលាយជាមួយទឹក ១៧ លីត្រ ។

-ខ្ចប់របស់ដែលមានក្លិនស្អុយជានុយដាក់ជុំវិញស្រែនិងក្នុងស្រែឬក៏លាយថ្នាំពុលជាមួយនុយនោះដោយព្យួរនៅក្នុងស្រែ ពីព្រោះសត្វស្រឹង